# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ៦៦៥/០៥ គ.ជ.ប

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ** : សំណើសុំចេញសេចក្តីណែនាំដល់ប្រជាពលរដ្ឋដើម្បីបង្ការកុំឱ្យប្រជាពលរដ្ឋប្រើគ្រឿងស្រវឹងនៅថ្ងៃមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។

**យោង** : -ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។

-បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៨ ។

តាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានកិត្តិយសសូមជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា ក្នុងគោលបំណងឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៨ នេះ ប្រព្រឹត្តទៅប្រកបដោយបរិយាកាស សន្តិសុខល្អ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ និងបាតុភាពនានាដែលអាចកើតមានឡើងដោយសារការប្រើប្រាស់គ្រឿងស្រវឹង ។ ដូច្នេះ គ.ជ.ប សូមស្នើសុំសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចេញសេចក្តីណែនាំដល់ប្រជាពលរដ្ឋដើម្បីបង្ការកុំឱ្យប្រជាពលរដ្ឋប្រើគ្រឿងស្រវឹងនៅថ្ងៃមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត គឺថ្ងៃទី ២៦-២៧ ខែ កក្កដា ឆ្នាំ ២០០៨ ដូចដែលរាជរដ្ឋាភិបាលធ្លាប់បានធ្វើក្នុងសម័យបោះឆ្នោតលើកមុនៗ ។

អាស្រ័យហេតុនេះ សូមសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាពិនិត្យ និងសម្រេចតាមការគួរ ។

សូមសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អ៊ឹម សូស៊ីត